លេខ ៣ ចេញផ្សាយថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែសីហា ឆ្នាំ២០២១

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## មាតិកា


- គោលបំណងទទួលបានធាតុចូលបន្ថែមពីភាគីពាក់ព័ន្ធដែលមានការចូលរួមពីក្រុមហ៊ុនគ្រប់គ្រងមូលនិធិ និងក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស ទំព័រ ២
- គោលបំណងទទួលបានធាតុចូលបន្ថែមពីភាគីពាក់ព័ន្ធដែលមានការចូលរួមពីបុគ្គលបរធនបាលកំពុងធ្វើប្រតិបត្តិការបរធនបាលកិច្ចហិរញ្ញវត្ថុ ទំព័រ ២
- គោលបំណងទទួលបានធាតុចូលបន្ថែមពីភាគីពាក់ព័ន្ធដែលមានការចូលរួមពីតំណាងធនាគារជាតិនៃកម្ពុជា ទំព័រ ៣


## កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពី “វិធានគោលក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច”




រូបភាពក្នុងកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពី “វិធានគោលក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច” តាមប្រព័ន្ធអនឡាញ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ ដារ៉ា**។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## គោលបំណងទទួលបានធាតុចូលបន្ថែមពីភាគីពាក់ព័ន្ធដែលមានការចូលរួមពីក្រុមហ៊ុនគ្រប់គ្រងមូលនិធិ និងក្រុមហ៊ុនថៃរក្សាទ្រព្យសម្បត្តិជំនួស

នាព្រឹកថ្ងៃចន្ទ ៩រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី២ ខែសីហា ឆ្នាំ២០២១ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយឯកឧត្តមអគ្គនាយករង និងមន្ត្រីជំនាញ បានដឹកនាំកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពី "វិធានគោលក្នុងការគ្រប់-គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច" ក្នុងគោលបំណងទទួលបានធាតុចូលបន្ថែមពីភាគីពាក់ព័ន្ធ ដែលមានការចូលរួមពីក្រុមហ៊ុនគ្រប់គ្រងមូលនិធិ និងក្រុមហ៊ុនថៃរក្សាទ្រព្យសម្បត្តិជំនួស។

សេចក្តីព្រាងប្រកាសនេះ មានគោលបំណងគ្រប់គ្រងរាល់សកម្មភាព និងប្រតិបត្តិការបរធនបាលកិច្ចក្នុងការគ្រប់គ្រងចាត់ចែង និងថែរក្សាទ្រព្យសម្បត្តិជំនួសឱ្យអ្នកដទៃ ដើម្បីជាប្រយោជន៍ដល់អត្ថគាហកៈ ឬបុគ្គលណាមួយ ដោយកំណត់អំពីលក្ខខណ្ឌ និងនីតិវិធីក្នុងការផ្តល់ការអនុញ្ញាតពី **ន.ប.ធ.** ឱ្យបង្កើតដំណើរការ និងចុះបញ្ជីបរធនបាលកិច្ច ព្រមទាំងការផ្តល់អាជ្ញាបណ្ណ និង/ឬការអនុញ្ញាតដល់ប្រតិបត្តិករបរធនបាល តាមរយៈការកំណត់សិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវក្រោមលក្ខខណ្ឌអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតនោះ។



រូបភាពក្នុងកិច្ចប្រជុំដែលមានការចូលរួមពីក្រុមហ៊ុនគ្រប់គ្រងមូលនិធិ និងក្រុមហ៊ុនថៃរក្សាទ្រព្យសម្បត្តិជំនួស តាមប្រព័ន្ធអនឡាញ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ ដារ៉ា**។

## គោលបំណងទទួលបានធាតុចូលបន្ថែមពីភាគីពាក់ព័ន្ធដែលមានការចូលរួមពីបុគ្គលបរធនបាលកំពុងធ្វើប្រតិបត្តិការបរ-ធនបាលកិច្ចហិរញ្ញវត្ថុ

នាព្រឹកថ្ងៃអង្គារ ១០រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី៣ ខែសីហា ឆ្នាំ២០២១ ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយឯកឧត្តមអគ្គនាយករង និងមន្ត្រីជំនាញ បានដឹកនាំកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពី "វិធានគោលក្នុងការគ្រប់-គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច" ក្នុងគោលបំណងទទួលបានធាតុចូលបន្ថែមពីភាគីពាក់ព័ន្ធ ដែលមានការចូលរួមពីបុគ្គលបរធនបាលកំពុងធ្វើប្រតិបត្តិការបរធនបាល-កិច្ចហិរញ្ញវត្ថុ។

សេចក្តីព្រាងប្រកាសនេះ មានគោលបំណងគ្រប់គ្រងរាល់សកម្មភាព និងប្រតិបត្តិការបរធនបាលកិច្ចក្នុងការគ្រប់គ្រងចាត់ចែង និងថែរក្សាទ្រព្យសម្បត្តិជំនួសឱ្យអ្នកដទៃ ដើម្បីជាប្រយោជន៍ដល់អត្ថគាហកៈ ឬបុគ្គលណាមួយ ដោយកំណត់អំពីលក្ខខណ្ឌ និងនីតិវិធីក្នុងការផ្តល់ការអនុញ្ញាតពី **ន.ប.ធ.** ឱ្យបង្កើតដំណើរការ និងចុះបញ្ជីបរធនបាលកិច្ច ព្រមទាំងការផ្តល់អាជ្ញាបណ្ណ និង/ឬការអនុញ្ញាតដល់ប្រតិបត្តិករបរធនបាល តាមរយៈការកំណត់សិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវក្រោមលក្ខខណ្ឌអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតនោះ។



រូបភាពក្នុងកិច្ចប្រជុំដែលមានការចូលរួមពីបុគ្គលបរធនបាលកំពុងធ្វើប្រតិបត្តិការបរធនបាលកិច្ចហិរញ្ញវត្ថុ តាមប្រព័ន្ធអនឡាញ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **សុខ ដារ៉ា**។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## គោលបំណងទទួលបានធាតុចូលបន្ថែមពីភាគីពាក់ព័ន្ធដែលមានការចូលរួមពីតំណាងធនាគារជាតិនៃកម្ពុជា

នាព្រឹកថ្ងៃសុក្រ ៥រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥ ត្រូវនឹងថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២១ ឯកឧត្តម **ឈើ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តម **សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយមន្ត្រីជំនាញ បានដឹកនាំកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងប្រកាសស្តីពី "វិធានគោលក្នុងការគ្រប់គ្រង ការរៀបចំ និងការប្រព្រឹត្តទៅរបស់បរធនបាលកិច្ច" ក្នុងគោលបំណងទទួលបានធាតុចូលបន្ថែមពីភាគីពាក់ព័ន្ធដែលមានការចូលរួមពីតំណាងធនាគារជាតិនៃកម្ពុជាផងដែរ។

សេចក្តីព្រាងប្រកាសនេះ មានគោលបំណងគ្រប់គ្រងរាល់សកម្មភាព និងប្រតិបត្តិការបរធនបាលកិច្ចក្នុងការគ្រប់គ្រងចាត់ចែង និងថែរក្សាទ្រព្យសម្បត្តិជំនួសឱ្យអ្នកដទៃ ដើម្បីជាប្រយោជន៍ដល់អត្ថគាហកៈ ឬបុគ្គលណាមួយ ដោយកំណត់អំពីលក្ខខណ្ឌ និងនីតិវិធីក្នុងការផ្តល់ការអនុញ្ញាតពី **ន.ប.ធ.** ឱ្យបង្កើតដំណើរការ និងចុះបញ្ជីបរធនបាលកិច្ច ព្រមទាំងការផ្តល់អាជ្ញាបណ្ណ និង/ឬការអនុញ្ញាតដល់ប្រតិបត្តិករបរធនបាល តាមរយៈការកំណត់សិទ្ធិ កាតព្វកិច្ច និងការទទួលខុសត្រូវក្រោមលក្ខខណ្ឌអាជ្ញាបណ្ណ និង/ឬការអនុញ្ញាតនោះ។




រូបភាពក្នុងកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ ដែលមានការចូលរួមពីតំណាងធនាគារជាតិនៃកម្ពុជា ក្រោមការដឹកនាំរបស់ឯកឧត្តម **ឈើ សាគល**។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888